**មាត្រា ២** : គណៈកម្មការមានភារកិច្ចចាត់ចែងពិធីបុណ្យសព តាមប្រពៃណី និង ទំនាក់ទំនងបណ្ដាស្ថាប័ន ដែលមានការពាក់ព័ន្ធ ដើម្បីដំណើរការបុណ្យសពនេះអោយបានអធិកអធម ។

**មាត្រា ៣** : សហរដ្ឋមន្ត្រីទទួលបន្ទុក ទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ អគ្គបញ្ជាការដ្ឋាន និង សាម៉ីខ្លួនត្រូវអនុវត្តន៍ តាមសេចក្ដីសំរេចនេះ ចាប់ពីឡាយ ព្រះហស្ដលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្ដលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

# II ការងារបណ្ដាក្រសួង

## ១–ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ០៨០ សហវ.ប្រក**

**ស្ដីពីការបង្កើតគណៈកម្មការបច្ចេកទេសម្របសំរួល**

**និងកែទំរង់រដ្ឋបាលប្រចាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

– បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

– បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាស

អោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស.រកម ០១៩៦.១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦ នស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤
- បានឃើញលិខិតលេខ ២៦៧ សជណគបរ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ១៩៩៦ ស្តីពីសំណើ រៀបចំគណៈកម្មការបច្ចេកទេសកែទំរង់រដ្ឋបាលតាមក្រសួង និង រដ្ឋលេខាធិការដ្ឋានរបស់ ទីស្តីការគណៈរដ្ឋមន្ត្រី ។
- បានឃើញតំរូវការចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១** :បង្កើតគណៈកម្មការបច្ចេកទេសសម្របសំរួល និង កែទំរង់រដ្ឋបាលប្រចាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| -ឯកឧត្តម **ឆាយ ថន** | អនុរដ្ឋលេខាធិការ | សហប្រធាន |
| -ឯកឧត្តម **ជា ប៉េងឈាង** | អនុរដ្ឋលេខាធិការ | |
| -លោក **សារាក់ ខាន់** | នាយកខុទ្ទកាល័យ | អនុប្រធាន |
| -លោក **មោក សុធារិន** | ប្រធាននាយកដ្ឋានបុគ្គលិក | អនុប្រធាន |
| -លោក **ខុច ឡេង** | ប្រធាននាយកដ្ឋានថវិការដ្ឋ | សមាជិក |
| -លោក **ស ហួរ** | នាយកទីចាត់ការគយរដ្ឋាករ | សមាជិក |
| -លោក **ខិន ឃន** | ប្រធានរតនាគារជាតិ | សមាជិក |
| -លោក **សាម ម៉ិនហេង** | ប្រធាននាយកដ្ឋានហិរញ្ញកិច្ច | សមាជិក |
| -លោក **យីនន៍ ត័យឈន់** | ប្រធាននាយកដ្ឋានរបបគណនេយ្យ | សមាជិក |
| -លោក **ហុង ថា** | ប្រធាននាយកដ្ឋានពន្ធដារ | សមាជិក |

- លោក ជូ គឹមឡេង ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស សមាជិក
- លោក ឡោក់ ឡេង ប្រធានអង្គភាពមន្ទីរ សមាជិក
- លោក ទន្សូ វ៉ូដោទុន្ត នាយកសាលាមធ្យមសិក្សាហិរញ្ញវត្ថុ សមាជិក
- លោក ករ៉ាង ឈាងច័ណ្ឌ ប្រធាននាយកដ្ឋានទុនវិនិយោគក្នុងនាមូលដ្ឋាន សមាជិក
- លោក ស៊ុន គឹមស្រ៊ុន អនុប្រធាននាយកដ្ឋានទុនវិនិយោគក្នុងនាមូលដ្ឋាន សមាជិក
- លោក អ៊ុន ឥវ៉ាងអ៊ីម ប្រធានក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា សមាជិក
- លោក ខុច ហៃ ប្រធានការិយាល័យបុគ្គលិក សមាជិក
- លោក ស៊ុន ចន្ទ្រី ប្រធានការិយាល័យក្របខ័ណ្ឌបៀវត្ស សមាជិក

**ប្រការ ២** : គណៈកម្មការបច្ចេកទេសសំរបសំរួល និង កែទំរង់រដ្ឋបាលប្រចាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចចូលរួមសហការ និង បង្កលក្ខណៈងាយស្រួលដល់គណៈប្រតិភូរបស់ គណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង ដើម្បីកែទំរង់រដ្ឋបាលដោយមានការចូលរួមពីអ្នកជំនាញការ UNDP សំរេចភារកិច្ចជោគជ័យលើការងារកែទំរង់រដ្ឋបាលនៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៣** : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានមន្ទីរ និង សាមីខ្លួនដូចក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ហត្ថលេខា និង ត្រា

**គាត ឈន់**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៩៦

## ប្រកាសលេខ ១៧១ សហវ.ប្រក

## ការបង្កើតការិយាល័យពត៌មានវិទ្យា

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ